# ធនធានយានជំនិះ (ពហុក្រុង) ខោនធី Los Angeles

**<u>ACCESS SERVICES, INC. (ខោនធី Los Angeles)</u>**

**ទូរស័ព្ទ៖** (800) 827-0829
*សំរាប់បុគ្គលមានពិការភាពសោតវិញ្ញាណ និងការប្រាស្រ័យទាក់ទង៖* (800) 827-1359
**គេហទំព័រ៖** http://accessla.org/home/

**សេវា៖** សេវាយានជំនិះ នៅសព្វខោនធី Los Angeles សំរាប់បុគ្គលមានពិការភាព។ ហៅលេខឥតគិតថ្លៃ និងទូរស័ព្ទការីនៃ Access Services នឹងផ្ញើឲ្យពាក្យសុំ និងកញ្ចប់ព័ត៌មាន។ បន្ទាប់ពីទទួលពាក្យសុំមក ការសំភាសន៍មួយនឹងបានគ្រោងពេលជាមួយអ្នកវាយតម្លៃនៃ Access Services ដើម្បីសំរេចសិទ្ធិទទួល សំរាប់បើប្រាស់ប្រព័ន្ធ។ ក្មេងៗត្រូវតែមានអាយុលើសពី 6 ឆ្នាំ ដើម្បីចុះឈ្មោះបាន។

ព័ត៌មានទូទៅ៖

- Access គឺជាសេវាជិះឡានចូលគ្នា ពីចិញ្ចើមថ្នល់មួយទៅមួយទៀត។
- អ្នកជិះច្រើននាក់ នឹងបានដឹកជញ្ជូននៅពេលម្តង ក្នុងរថយន្តដូចគ្នា។
- វាគឺមិនមែនជាសេវាឡានតាកស៊ី ឡានពេទ្យគ្រាអាសន្ន ឬសេវាយានជំនិះសង្គម សេវាពីទ្វារមួយទៅមួយទៀត ឬយានជំនិះឯកជនឡើយ។
- Access ផ្តល់សេវាបិតក្នុងចំងាយ ¾ ម៉ាល នៃផ្លូវឡានបឹសបានកំណត់ និងខ្សែរថភ្លើង ក្នុងខោនធី Los Angeles។
- Access ប្រតិបត្តិការតាមកាលវិភាគ ដូចគ្នានឹងឡានបឹសភាគច្រើន។ សេវាទៀងទាត់ គឺផ្តល់ជូនពីម៉ោង 4:00 ព្រឹក ដល់ 12:00 ព្រឹក 7 ថ្ងៃ មួយអាទិត្យ។
- ដូចគ្នានឹងសេវាជិះចូលគ្នាដែរ ពេលវេលាធ្វើដំណើររបស់អ្នក នឹងស្រដៀងទៅនឹងផ្លូវឡានបឹសបានកំណត់ មិនមែនជាឡាន ឬឡានតាក់ស៊ីទេ។
- ថ្លៃជិះ ដំណើរមួយជើងរបស់អ្នក គឺយោងលើចំងាយដែលអ្នកធ្វើដំណើរ ដោយមានថ្លៃជិះអតិបរិមា $3.25 (លើកលែងតែទៅ/មក និងនៅក្នុង Antelope និង Santa Clarita Valleys)។ អ្នកបំរុងកន្លែងទុក នឹងប្រាប់អ្នកអំពីថ្លៃជិះរបស់អ្នក នៅពេលអ្នកគ្រោងពេលធ្វើដំណើររបស់អ្នក។

**តម្លៃ៖**

| | |
|---|---|
| 0 ទៅ 19.9 ម៉ាល | $2.50 |
| 20 ឬច្រើន ម៉ាល | $3.25 |

សារៈសំខាន់៖ Access មិនអាចនឹងដឹកជញ្ជូនរទេះកៅអី ឬឧបករណ៍ចល័ត មានទទឹងធំជាង 30” និងប្រវែង 48” និងមានទំងន់ធ្ងន់ជាង 600lbs នៅពេលមនុស្សបានជិះឡើយ។

មើលគេហទំព័រ ឬទាក់ទង Access Services ដើម្បីឲ្យបាន៖

- មគ្គុទ្ទេសក៍អ្នកជិះ Access/Access Rider's Guide
- ព័ត៌មានអំពីសិទ្ធិទទួល/Information about eligibility
- ពាក្យសុំការហ្វឹកហ្វឺនធ្វើដំណើរ/Travel Training Application
- ព័ត៌មានស្តីពីរបៀបប្តឹងបណ្តឹង/Information on how to file a complaint

**METROPOLITAN TRANSPORTATION AUTHORITY (MTA) អាជ្ញាធរយានជំនិះ ប្រជុំក្រុង LOS ANGELES**

**ទូរស័ព្ទ៖** (800) 266-6883

**គេហទំព័រ៖** https://www.metro.net/

**សេវា៖** សេវាឡានបឹស។

**តម្លៃ៖** បន្ថយថ្លៃជិះ ដោយមាន អត្តសញ្ញាណប័ណ្ណពិការរបស់ Metro/ Metro's Disabled ID Card។

ដើម្បីឲ្យបានប័ណ្ណ ID ពិការរបស់ Metro អ្នកត្រូវតែផ្តល់ភស្តុតាងនៃសិទ្ធិទទួល ឬប័ណ្ណ Medicare។ ពាក្យសុំគឺមាននៅមណ្ឌលអតិថិជន Metro ឬតាមអនឡាញ។ ពាក្យសុំដែលបានបំពេញ ត្រូវមានរូបថតមុខពេញ ឯកសារបានតម្រូវ និងថ្លៃឈ្នួល $2 អាចនឹងបានបញ្ជូនទៅ មណ្ឌលអតិថិជន Metro ណាមួយ។

ដើម្បីជួយជនមានឱនថយចក្ខុវិស័យ ទាំងនោះថែមទៀត Metro ក៏ផ្តល់អក្សរប្រ៊ោល មានលេខកូដ និងពុម្ពអក្សរធំៗ "Metro Flash Books" សំរាប់ឲ្យសញ្ញាទៅឡានបឹសត្រឹមត្រូវ។ សំរាប់ព័ត៌មានថែមទៀត សូមហៅ (213) 922-7023។

---

**METROLINK (រថភ្លើងតាមភូមិភាគ)**

**ទូរស័ព្ទ៖** (800) 371-5465

សូមហៅ 800-371-LINK(5465) ឬ 800-698-4TDD(4833) សំរាប់អតិថិជនដែលឱនថយសំដី និងសោតវិញ្ញាណ។

**គេហទំព័រ៖** https://metrolinktrains.com/

**សេវា៖** សេវារថភ្លើង ដោយមានការសំរបសំរួល៖

- ឡានរថភ្លើងនិមួយៗ មានបន្ទប់ទឹកអាចចេញចូលបានពេញលេញ។
- អ្នកចាំថែទាំផ្ទាល់ខ្លួន ជិះឥតគិតថ្លៃ ជាមួយអ្នកដំណើរដែលពិការ។
- សេវាសត្វចិញ្ចឹម គឺស្វាគមន៍។
- អ្នកដំណើរដែលត្រូវការជំនួយ ក្នុងការឡើងជិះ គួរតែរង់ចាំនៅលើផ្លូវជំរាលចេញចូល បិតនៅខាងចុងនៃលានរាប។

ដោយមានសំណើ 48 ម៉ោង ជាមុន អ្នកតំណាង Metrolink អាចផ្តល់ជំនួយ នៅឯស្ថានីយ។

**តម្លៃ៖** មានបន្ថយថ្លៃជិះ សំរាប់មនុស្សមានពិការភាព។ សូមបង្ហាញភស្តុតាងនៃសិទ្ធិទទួល ទៅអ្នកត្រួតពិនិត្យថ្លៃជិះ តាមសំណូមពរ៖

- អត្តសញ្ញាណប័ណ្ណ សមាគមអ្នកប្រតិបត្តិការយានស្ថាន/Transit Operators Association ID Card ខោនធី L.A.
- អត្តសញ្ញាណប័ណ្ណ បន្ថយថ្លៃជិះ/Reduced fare ID Card មកពីប្រព័ន្ធយានស្ថានមួយទៀត
- អត្តសញ្ញាណប័ណ្ណ Medicare/Medicare ID Card
- អត្តសញ្ញាណប័ណ្ណ និមិត្តប័ណ្ណ DMV/DMV placard ID Card
- អ្នកកាន់ប័ណ្ណ Access Services ID នៅខោនធី Los Angeles ជិះឥតអស់ថ្លៃ

---

## METRO MICRO

**ទូរស័ព្ទ៖** (323) 466-3876 (323-GO-METRO)
**គេហទំព័រ៖** https://micro.metro.net/

**សេវា៖**

- សេវា គឺបានផ្ដល់នៅក្នុងរថយន្តមួយ ដែលនឹងធ្វើដំណើរជិតៗ បិតក្នុងតំបន់ជាច្រើន ក្នុងខោនធី Los Angeles
- ដំណើរជិតៗតាមតំបន់ ដោយប្រើរថយន្តតូច (អ្នកដំណើរដល់ទៅ 10 នាក់)
- ដំណើរត្រូវបានគ្រោងពេល តាមតម្រូវការ ឬបានកក់ទុកជាមុន (ដល់ទៅ 7 ថ្ងៃ) ជាជាងការត្រូវរៀបចំគំរោងការធ្វើដំណើរទៅមក តាមកាលវិភាគផ្លូវឡានបឺស
- កក់ដំណើរទុក ជាមួយអាព្លចល័ត Metro Micro នៅលើគេហទំព័រ ឬដោយហៅ 323-GO-METRO

**តម្លៃ៖** $1 (មិនបញ្ចូលការដូរទៅឡានបឺស ឬរថភ្លើងទេ)

- អាចបង់ប្រាក់បាន ដោយប្រើប័ណ្ណ TAP ឬប័ណ្ណឥណទាន បានភ្ជាប់ទៅគណនី Metro Micro

---

## សាធារណៈការ/ PUBLIC WORKS ខោនធី LOS ANGELES

**អាសយដ្ឋាន៖** 900 S. Fremont Avenue
Alhambra, CA
**ទូរស័ព្ទ៖** (626) 458-5100
**គេហទំព័រ៖** https://pw.lacounty.gov/transit/

**សេវា៖**

- ផ្ដល់សេវាយានជំនិះ សំរាប់ព្រឹទ្ធាវ័យមានសិទ្ធិទទួល និងអ្នកមូលដ្ឋានដែលពិការ នៅតំបន់មិនទាន់បានបញ្ចូលនៃខោនធី Los Angeles។ ផែនទីមានអន្តរសកម្ម អនុញ្ញាតឲ្យអ្នកជ្រើសរើសក្រុងរបស់អ្នក ដើម្បីឲ្យបានប្រាប់ផ្លូវទៅ យានស្ថានជនពិការ/សេវា Dial-A-Ride នៃក្រុងរបស់អ្នក។

---

## SOCAL 511

**ទូរស័ព្ទ៖** ចុចលេខ - 511
**គេហទំព័រ៖** www.Go511.com

**សេវា៖**

- ប្រជាជនអាចហៅ Southern California 511 មកពីកន្លែងណាមួយ ក្នុងខោនធី Los Angeles, Orange, Riverside, San Bernardino និង Ventura មកពីទូរស័ព្ទខ្សែ ឬទូរស័ព្ទដៃ។ សេចក្ដីណែនាំសមញ្ញ នឹងណែនាំអ្នកទៅរកព័ត៌មានដែលអ្នកត្រូវការ – ដោយប្រើបន្ទះទូរស័ព្ទប៉ះឮសូរ ឬនិយាយ អ្នកចង់បានអ្វី ហើយលេខ 511 នឹងផ្ដល់ឲ្យព័ត៌មានដែលអ្នកបានស្នើ។
- គេហទំព័រ ផ្ដល់ជូនមាតិកាសាមញ្ញ ដើម្បីជួយប្រជាជនរកព័ត៌មានយ៉ាងឆាប់រហ័ស និងគ្រោងផ្លូវត្រឹមត្រូវ សំរាប់ដំណើររបស់គេ។ ទីតាំងនោះផ្ដល់ជូន ផែនទីចរាចរណ៍ អន្តរសកម្មរស់រវើក ដើម្បីមើលចរាចរណ៍នៅក្នុងតំបន់ ឬទស្សនា "ឡានបឺស និងរថភ្លើង/Buses and Trains" ដើម្បីរកសេវាយានស្ថានត្រឹមត្រូវ សំរាប់ដំណើររបស់អ្នក។